**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៧៧១ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតក្រុមការងារសម្របសម្រួលជាមួយ សាធារណរដ្ឋប្រជាមានិតចិន លើកិច្ចការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជាទៅទីផ្សារចិន**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស០១៩៦/១៦/រកម/ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- តាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

**សម្រេច**

**មាត្រា១.** ត្រូវបានបង្កើតក្រុមការងារសម្របសម្រួលជាមួយ សាធារណរដ្ឋប្រជាមានិតចិន លើកិច្ចការជំរុញការនាំចេញផលិតផលកសិកម្មរបស់កម្ពុជាទៅកាន់ទីផ្សារចិន។

**មាត្រា២.** ត្រូវបានកំណត់សមាសភាពនៃក្រុមការងារ ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **សាន វណ្ណាទី** | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាប្រធាន |
| ២. ឯកឧត្តម **ខេង សុធី** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ជាអនុប្រធាន |
| ៣. ឯកឧត្តម **សូ ខនច្ចន្ទីគុណា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម | ជាសមាជិក |

៤.ឯកឧត្តម **កែ សុវណ្ណ** អគ្គនាយកជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម ជាសមាជិក

៥.លោកបណ្ឌិត **ហ៊ាន វណ្ណហាន** អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

៦.លោក **ឈាវ ផា** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ ក្រសួងពាណិជ្ជកម្ម ជាសមាជិក

៧.លោក **យូ ម៉ាប់** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន ក្រសួងពាណិជ្ជកម្ម ជាសមាជិក

៨.លោក **ហេង ឈុនហ៊ី** អនុប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

**មាត្រា៣.** ក្រុមការងារនេះ មានភារកិច្ចធ្វើការសម្របសម្រួល និងទំនាក់ទំនងជាមួយ ភាគីចិន ជាពិសេសជាមួយអគ្គរដ្ឋបាលគ្រប់គ្រង ត្រួតពិនិត្យគុណភាព និងចត្តាឡីស័ក្តរបស់ចិន (AQSIQ) ដើម្បីរៀបចំសំណុំឯកសារ បែបបទ ក្នុងការបង្កើតនូវពិធីសារអនាម័យ និងភូតគាមអនាម័យ រវាងកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន សម្រាប់ផលិតផលកសិកម្មកម្ពុជា ក្នុងគោលបំណងជំរុញការនាំចេញផលិតផលទាំងនោះទៅកាន់ទីផ្សារចិន។ ក្រុមការងារនេះ មានភារកិច្ច បំពេញការងារពាក់ព័ន្ធដទៃទៀត ជាមួយភាគីចិន ដើម្បីជំរុញការបើកច្រកទីផ្សារចិន សម្រាប់កសិផលកម្ពុជា។

**មាត្រា៤.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងមាត្រា២ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ៩(៧) ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ដូចមាត្រា៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ